FLO
Building resourceful communities

អត្ថបទស្តីពីភាពជោគជ័យនៃគម្រោង

# ការសន្សំប្រាក់ ធ្វើឱ្យសមាជិកក្រុមមានជីវភាពធូរធារ

ក្រោមក្របខ័ណ្ឌនៃកម្មវិធីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅសហគមន៍ អង្គការដើម្បីជីវភាព និងព្រៃឈើ (FLO) បានចងក្រងឱ្យមានក្រុមសន្សំប្រាក់ចំនួនសរុប១២ក្រុម នៅក្នុង៥ឃុំនៃខេត្តក្រចេះ សំដៅកាត់បន្ថយចំណាកស្រុក និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសក្នុងចំណោមសមាជិកក្រុមសន្សំទាំងអស់។

ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ (ក្រុងក្រចេះ)

អ្នកស្រី ខេត មុំ អាយុ៥០ឆ្នាំ គឺជាសមាជិកក្រុមសន្សំក្នុងចំណោមសមាជិកសន្សំចំនួន២២នាក់ ដែលរស់នៅក្នុងភូមិទ្រាប ឃុំថ្មី ស្រុកសុចិត្របុរី ខេត្តក្រចេះ ធ្លាប់ទទួលបានការបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុ ដែលផ្តល់ដោយអង្គការដើម្បីជីវភាព និងព្រៃឈើ (FLO)។ បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលរួមមក អ្នកស្រីបានចូលជាសមាជិកក្រុមសន្សំ ដោយបានដាក់ប្រាក់សន្សំរបស់ខ្លួនចំនួន៥000 ទៅ១០,000 រៀលក្នុងមួយខែ។ លោកស្រី ខេត មុំ បានបញ្ជាក់ឱ្យដឹងថា *"ខ្ញុំបានសម្រេចចិត្តចូលជាសមាជិកក្រុមសន្សំ ដោយសារខ្ញុំអាចខ្ចីប្រាក់ក្នុងក្រុមដើម្បីបង្កើនមុខរបរបន្ថែម។ ថ្មីៗនេះខ្ញុំបានខ្ចីប្រាក់សន្សំចំនួនមួយលានរៀល ដើម្បីគ្រឿងទេសលក់ដូរនៅផ្ទះ និងអាចរកប្រាក់ចំណូលដោះស្រាយជីវភាពក្នុងក្រុមគ្រួសារបាន។*



អ្នកស្រី ខេត មុំ សមាជិកក្រុមសន្សំដែលបានខ្ចីប្រាក់យកទៅទិញគ្រឿងទេសសម្រាប់លក់ដូរនៅផ្ទះ។ កាលពីមុន អ្នកស្រីលក់ដូរគ្រឿងទេសតែបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែពេលនេះគាត់មានច្រើនមុខ ហើយអាចរកប្រាក់ចំណេញបានច្រើនជាងមុនផងដែរ។

ចំណែកលោកប្រាជ្ញ ទុំ អាយុ៦២ឆ្នាំ ដែលជាប្រធានគណៈកម្មការក្រុមសន្សំបានឱ្យដឹងថា *"ការខ្ចីប្រាក់ត្រូវមានកិច្ចសន្យា និងសាក្សីត្រឹមត្រូវ។ ការទូទាត់កម្ចីម្តងៗត្រូវមានរយៈពេល៦ខែ ហើយត្រូវសងត្រឡប់ដោយការបង់រម្លស់ទាំងដើមទាំងការ។* លោក ប្រាជ្ញ ទុំ បានបន្ថែមថា *"គ្មានបញ្ហាអ្វីឡើយទាក់ទងនឹងការខ្ចី និងការសងត្រឡប់ ហើយសមាជិកក៏មានចំនួនកើនឡើងផងដែរ។ មកដល់ពេលនេះ ប្រាក់សន្សំសរុបមានចំនួន១៣លានរៀល ក្នុងនោះជាង៣លានរៀលត្រូវបានសមាជិកខ្ចីយកទៅប្រើប្រាស់ជាបន្តបន្ទាប់។"*

លោក មុំ ខាំ ប្រធានក្រុមប្រឹក្សាឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ បានគូសបញ្ជាក់ថា *"ក្នុងនាមអាជ្ញាធរមូលដ្ឋាន យើងខ្ញុំសូមអរគុណចំពោះអង្គការ FLO ដែលបានផ្តល់ជាទុនសម្រាប់ក្រុមសន្សំ ដើម្បីពង្រីកមុខរបររបស់ប្រជាពលរដ្ឋឱ្យមានជីវភាពធូរធារ និងជៀសវាងការធ្វើចំណាកស្រុកទៅធ្វើការនៅទីឆ្ងាយ ឬខ្ចីបុលអ្នកចងការដែលមានអត្រាការប្រាក់ខ្ពស់។"*



លោក ប្រាជ្ញ ទុំ ប្រធានគណៈកម្មការក្រុមសន្សំ កំពុងពិនិត្យបញ្ជីបូកសរុបប្រាក់សន្សំ និងប្រាក់កម្ចី ដែលសមាជិកទាំងអស់យកទៅប្រើប្រាស់តាមតម្រូវការរបស់ខ្លួន ស្របតាមលក្ខន្តិកៈរបស់ក្រុមសន្សំប្រាក់។

កាលពីឆ្នាំ២០១២ អង្គការ FLO បានផ្តល់ទុនសរុបចំនួន១,៦ លានរៀល ក្រោមជំនួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្នុងក្រោមក្របខ័ណ្ឌនៃកម្មវិធីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅសហគមន៍។ ជាទូទៅសមាជិកក្នុងក្រុមបានខ្ចីប្រាក់សន្សំក្នុងអត្រាការប្រាក់ចំនួន៣% ដើម្បីយកទៅពង្រីកមុខរបរ ទិញសម្ភារៈកសិកម្ម ទិញកូនជ្រូកមកចិញ្ចឹម ទិញគ្រឿងសំណង់ធ្វើផ្ទះ និងសម្រាប់ប្រើប្រាស់ពេលមានអាសន្នក្នុងគ្រួសារជាដើម៕

Forest and Livelihood Organization (FLO)
House 660, Street 2, Tropaing Prieng village, Sangkat Kratie, Kratie town, Kratie Province.
E-mail: info@cambodia.org Tel: (+855) 72 5000 135 Website: www.flocambodia.org